**អភិបូជាបិទសន្និបាតយុវជនកាតូលិកភូមិភាគភ្នំពេញ**
**ព្រះសហគមន៍សន្តសិលា និងសន្តប៉ូល**
**ភ្នំពេញថ្មី ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១**
**“ទំនាក់ទំនង”**

បងប្អូនជាទីស្រឡាញ់
ថ្ងៃនេះ យើងមានសំណួរពិសេសដែលចេញពីព្រះយេស៊ូតែម្តង ព្រះអង្គមានព្រះបន្ទូលទៅគេថា “**តើមនុស្សទាំងឡាយថាខ្ញុំជានរណា?**”។ មនុស្សទាំងឡាយ ប្រសិនបើយើងទៅសួរដល់ប្រជាជនកម្ពុជាដែលជាពុទ្ធបរិស័ទ ឬឥស្លាមបរិស័ទ ថា **តើព្រះយេស៊ូជានរណា?** គេធ្លាប់ឮអំពីព្រះយេស៊ូដែរដូច្នេះប្រហែលគេមានចម្លើយមួយ ជាមនុស្សអស្ចារ្យ ជាអ្នកបង្កើតសាសនា ជាមនុស្សម្នាក់ដែលបានជួយអ្នកក្រីក្រយ៉ាងច្រើន ជាមនុស្សម្នាក់ដែលជាតំណាងរបស់ព្រះជាម្ចាស់លើផែនដីនេះ... នេះជាចម្លើយទូទៅ។ ប៉ុន្តែ បងប្អូនជាទីស្រឡាញ់ជាពិសេសយុវជនយុវនារី ថ្ងៃនេះយើងមានព្រះបន្ទូលមួយសម្រាប់យើងផ្ទាល់។ ថ្ងៃនេះ ព្រះយេស៊ូបានសួរដល់យើងដែលជាគ្រីស្តបរិស័ទ ជាសាវ័ករបស់ព្រះយេស៊ូ **ចុះអ្នករាល់គ្នាវិញតើអ្នករាល់គ្នាថាខ្ញុំជានរណា?** ខ្ញុំមិនអាចឆ្លើយជំនួសបងប្អូនទេ យើងរៀងៗខ្លួនយើងមានចម្លើយរបស់យើង។

ខ្ញុំចាំបានថា នៅពេលខ្ញុំរៀននៅវិទ្យាល័យថ្នាក់ទី១១ យើងមានម៉ោងរៀនអំពីសាសនាលោកគ្រូបានសួរថា **សម្រាប់យើងផ្ទាល់តើព្រះយេស៊ូជានរណា?** នៅពេលនោះ ដើម្បីបានចម្លើយខ្ញុំបានស្រាវជ្រាវក្នុងសៀវភៅយ៉ាងច្រើនរបស់ឪពុកខ្ញុំ ខ្ញុំបានសរុបសេចក្តីដែលខ្ញុំបានទទួលពីសៀវភៅទាំងនោះ ព្រះយេស៊ូជាព្រះគ្រីស្ត ព្រះយេស៊ូជាព្រះមេស៊ី ព្រះយេស៊ូបានធ្វើការអស្ចារ្យ...។ នៅពេលនោះ ខ្ញុំមិនទាន់មានចម្លើយផ្ទាល់ខ្លួនរបស់ខ្ញុំទេ ព្រោះទាំងនេះជាចម្លើយដែលចេញពីចំណេះដឹងច្រើនជាង។

តាមពិត បន្តិចម្តងៗខ្ញុំបានចូលនៅក្នុងបទពិសោធផ្ទាល់ជាមួយព្រះយេស៊ូ ព្រះយេស៊ូមិនមែនជាព្រះយេស៊ូដែលយើងបានរៀននៅក្នុងម៉ោងអប់រំជំនឿ ព្រះយេស៊ូមិនមែនជាមនុស្សម្នាក់ដែលយើងអាចស្គាល់ដោយគ្រាន់តែអានប្រវត្តិសាស្រ្តបានទេ។ ព្រះយេស៊ូជាព្រះជាម្ចាស់ដែលបានចាប់កំណើតជាមនុស្ស ដែលណែនាំឱ្យយើងចូលនៅក្នុងជីវិតរបស់ព្រះអង្គ។ ហេតុនេះហើយបន្តិចម្តងៗនៅក្នុងជីវិតរបស់យើងផ្ទាល់ យើងចាប់ផ្តើមបង្កើតទំនាក់ទំនងជាមួយព្រះយេស៊ូ។ ដូចពីយប់មិញ នៅពេលយើងអង្គុយក្បែរឈើឆ្កាង ដូចនៅប៉ុន្មានកន្លែងយើងអង្គុយនៅក្បែរព្រះកាយ ដូចនៅពេលយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាពេលវេលាដើម្បីបង្កើតទំនាក់ទំនងផ្ទាល់ជាមួយព្រះយេស៊ូ។ ហេតុនេះហើយ ចម្លើយរបស់យើងមិនចេញពីចំណេះដឹងមួយ មិនចេញពីសៀវភៅដែលស្តីអំពីព្រះយេស៊ូ ប៉ុន្តែចេញពីបទពិសោធផ្ទាល់ដែលយើងមាននៅក្នុងជីវិតរបស់យើង។

ចម្លើយដែលយើងបានទទួលពីលោកសិលាថា "**លោកជាព្រះគ្រីស្ត**" នៅពេលលោកសិលាបានឆ្លើយដូចនេះមិនមែនជាចម្លើយដែលមកពីចំណេះដឹងរបស់គាត់ មិនមែនជាចម្លើយនៅក្នុងការអប់រំជំនឿដែលគាត់បានទទួល។ ប៉ុន្តែ ជាចម្លើយដែលមកពីជំនឿរបស់គាត់ដែលគាត់បានទទួលពីព្រះជាម្ចាស់ផ្ទាល់។ ផ្ទាល់ខ្លួនគាត់មិនអាចមានចម្លើយដូចនេះបានទេ ប៉ុន្តែដោយសារគាត់មានបទពិសោធជាមួយព្រះយេស៊ូ ដើរជាមួយព្រះយេស៊ូ ហូបបាយជាមួយព្រះយេស៊ូ អធិដ្ឋានជាមួយព្រះយេស៊ូ ស្តាប់ព្រះយេស៊ូបង្រៀន មើលព្រះយេស៊ូបង្ហាញការអស្ចារ្យ ជួយអ្នកក្រីក្រ ជួយព្យាបាលអ្នកជំងឺ ជួយផ្តល់សេចក្តីសង្ឃឹមឱ្យប្រជាជន ជួយឱ្យម្តាយក្មេកគាត់ (លោកសិលា) បានជាពីជំងឺ គាត់បានឃើញផ្ទាល់។ នៅពេលគាត់បានឆ្លើយថា "**ព្រះយេស៊ូជាព្រះគ្រីស្ត**" មានន័យថាព្រះយេស៊ូជាព្រះសង្គ្រោះដែលណែនាំឱ្យយើងមានជីវិត។

បងប្អូនជាទីស្រឡាញ់ នៅក្នុងរយៈពេលបីថ្ងៃកន្លងមកនេះ យើងបានចែករំលែកបទពិសោធរបស់យើងដែរ។ គ្រប់បទពិសោធដែលយើងចែក ចេញពីបទពិសោធជាក់ស្តែងនៅក្នុងជីវិតយើង អំណរសប្បាយ សុបិន ទុក្ខលំបាក ការភ័យខ្លាច ការសង្ស័យ នេះជាបទពិសោធរបស់យើងទាំងអស់។ ប៉ុន្តែ នៅថ្ងៃទីមួយក្នុងអត្ថបទអេសាយបានបង្ហាញអំពីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់យើង។ ខ្ញុំបានឱ្យប្អូនរំលឹកដល់ថ្ងៃដែលចាប់កំណើតនៅលើផែនដីនេះ ដែលយើងបានទទួលជីវិតពីឪពុកម្តាយមែន ប៉ុន្តែដែលយើងទទួលជីវិតពីព្រះជាម្ចាស់។ ខ្ញុំបានណែនាំឱ្យបងប្អូនដែលទទួលអគ្គសញ្ញាជ្រមុជទឹកហើយ ឱ្យយើងនឹកឃើញដល់ថ្ងៃដែលយើងបានទទួលពិធីជ្រមុជទឹក ជាថ្ងៃដែលយើងទទួលយ៉ាងឱឡារិក ជាឋានៈពិសេសជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់

ជាថ្ងៃដែលយើងបានបំពាក់ព្រះយេស៊ូ។ នេះទាំងអស់ ជាបទពិសោធដែលយើងបានធ្វើ នៅក្នុងបទពិសោធ។ តាមពិតប្រសិនបើ យើងបើកភ្នែករបស់យើង បើកដួងចិត្តរបស់យើង នៅក្នុងបទពិសោធនីមួយៗមានវត្តមានរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ឥតមានវត្តមាននៅក្នុងសៀវភៅដែលយើងអាន ព្រះជាម្ចាស់ឥតមានវត្តមាននៅក្នុងមេរៀនដែលយើងរៀន ព្រះជាម្ចាស់មាននៅក្នុងបទពិសោធនៃជីវិតរបស់យើង។ ជីវិតរបស់យើងនៅពេលយើងអធិដ្ឋាន នៅពេលយើងបានទទួលអគ្គសញ្ញានានា នៅពេលយើងបានភ្ជាប់ជាមួយបងប្អូនឯទៀតៗ នៅពេលយើងលើកលែងទោសឱ្យគេ នៅពេលយើងខិតខំស្រឡាញ់មនុស្សទាំងអស់... នៅពេលហ្នឹងយើងមានបទពិសោធជាក់ស្តែងអំពីព្រះយេស៊ូ។

កុំភ្លេច អ្នកម្តាយតេរេសាដែលបានចាប់ផ្តើមណែនាំឱ្យសុបិនពិសេសរបស់គាត់កើតឡើង គឺនៅថ្ងៃដែលគាត់បានជួបជាមួយមនុស្សម្នាក់ដែលជិតស្លាប់នៅតាមផ្លូវ។ នៅពេលគាត់បានដើរហួសបន្តិច គាត់បាននឹកឃើញថាមុខអ្នកជំងឺនោះដូចជាបានភ្ជាប់ជាមួយព្រះភ័ក្ត្ររបស់ព្រះយេស៊ូនៅលើឈើឆ្កាង។ នៅពេលហ្នឹង គាត់មានបទពិសោធមួយយ៉ាងពិសេស នៅក្នុងអ្នកជំងឺដែលកំពុងជិតស្លាប់នៅតាមផ្លូវ តាមពិតគឺព្រះយេស៊ូផ្ទាល់ដែលកំពុងស្រេកទឹក ដែលកំពុងទន្ទឹងរង់ចាំសេចក្តីស្រឡាញ់។ ដូចពីព្រឹកមិញ ព្រះយេស៊ូអង្គុយនៅមាត់អណ្តូងទឹកដើម្បីចាំសុំទឹកពីស្ត្រីសាម៉ារីផ្ទុយទៅវិញនៅពេលស្ត្រីសាម៉ារីមានបទពិសោធជាមួយព្រះយេស៊ូផ្ទាល់ ជីវិតរបស់គាត់បានប្រែប្រួលអស់ហើយ។ ជីវិតរបស់គាត់ដែលប្រែប្រួលដោយផ្តាច់ចំណងដែលណែនាំឱ្យគាត់គាំ ដោយបើកព្រំដែនដែលណែនាំឱ្យគាត់ស្ទះនៅក្នុងជីវិតរបស់គាត់ពីយូរមកហើយ។ ដែលណែនាំឱ្យគាត់បង្កើតទំនាក់ទំនងសារជាថ្មីជាមួយបងប្អូននៅក្នុងភូមិ បង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែលត្រូវតែគោរពនៅក្នុងសេចក្តីពិតនិងព្រះវិញ្ញាណដ៏វិសុទ្ធ។

ទំនាក់ទំនង ជាបទពិសោធមួយដែលណែនាំឱ្យយើងភ្ញាក់ស្មារតីនៅក្នុងសម័យកូវីដ-១៩នេះ យើងបាត់ទំនាក់ទំនងផ្ទាល់ដោយសារកូវីដ-១៩។ ប៉ុន្តែ នៅពេលហ្នឹងយើងបាននឹកឃើញទំនាក់ទំនងផ្ទាល់សំខាន់ណាស់ ទំនាក់ទំនងជាមួយព្រះជាម្ចាស់ផ្ទាល់យើងមិនអាចបាត់បានទេ។ បន្តរស់នៅក្នុងសេចក្តីសង្ឃឹម និងជាពិសេសនៅក្នុងជំនឿដែលយើងបានទទួល។ សូមបងប្អូនអាចចាប់អារម្មណ៍អំពីអត្ថបទទី២ដែលយើងបានស្តាប់ថ្ងៃនេះ "**ប្រសិនបើបងប្អូនប្រុសស្រីណាម្នាក់គ្មានសម្លៀកបំពាក់ និងគ្មានម្ហូបអាហារបរិភោគរាល់ថ្ងៃ ហើយមានម្នាក់នៅក្នុងចំណោមបងប្អូនពោលទៅគាត់ថា សូមអញ្ជើញទៅដោយសុខសាន្ត សូមឱ្យបានកក់ក្តៅ សូមបរិភោគឱ្យបានឆ្អែត តែមិនឱ្យអ្វីដែលគេត្រូវការ តើពាក្យទាំងនេះមានប្រយោជន៍អ្វី?** សូមអញ្ជើញឱ្យបានសុខសាន្ត

សូមអញ្ជើញទៅរកម្ហូបអាហារ សូមមានភាពកក់ក្តៅ ប៉ុន្តែគាត់ឥតមានភួយដដែល គាត់ឥតមាន ម្ហូបអាហារដដែល។

នេះជាមូលហេតុ ដែលព្រះយេស៊ូមានព្រះបន្ទូលដល់ក្រុមគ្រីស្តទូតនៅពេលមានមហាជនប្រាំ ពាន់នាក់ ដែលកំពុងអង្គុយទន្ទឹងរង់ចាំម្ហូបអាហារ។ ព្រះយេស៊ូមិនបានបណ្តេញគេឱ្យទៅតាមផ្លូវ ដើម្បីរកចំណី ព្រះយេស៊ូបានប្រាប់ដល់ក្រុមគ្រីស្តទូតទាំង១២នាក់ដែលកំពុងបើកភ្នែកធំៗ ឱ្យម្ហូប ទៅគេចុះ។ **តើយើងធ្វើដូចម្តេចដើម្បីឱ្យម្ហូបទៅគេសម្រាប់ប្រាំពាន់នាក់?** យើងមានត្រីខ្លះៗ មាននំ ប៉័ងខ្លះៗ ឱ្យយើងទុកចិត្តលើព្រះជាម្ចាស់ទៅ។ ព្រះយេស៊ូបានយកនំប៉័ង និងត្រីហ្នឹងទូលអង្វរទៅ ព្រះបិតាដែលបានចិញ្ចឹមយើងរាល់ថ្ងៃ ហើយចែករំលែកឱ្យគេបានបរិភោគឆ្អែតទាំងអស់គ្នា។ នេះ ជាការអស្ចារ្យដែលយើងបានឃើញយ៉ាងជាក់ស្តែង មិនឱ្យគេទៅវិញ ឱ្យគេធ្វើទៅ ក្រុមគ្រីស្តទូត គេគាំងដោយសារគេនឹកមិនឃើញឫទ្ធានុភាពរបស់ព្រះជាម្ចាស់ គេមិនយល់អំពីបារមីដ៏ពិសេស របស់ព្រះយេស៊ូផ្ទាល់។ ដែលណែនាំឱ្យអ្វីដែលយើងគិតថា តាមមនុស្សយើងមិនអាចធ្វើបាន តាម ព្រះជាម្ចាស់អាចធ្វើបាន ដូចទេវទូតដែលបាននិយាយទៅព្រះនាងម៉ារីថា "**អ្វីៗទាំងអស់ព្រះជា ម្ចាស់អាចធ្វើបាន**" នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ក្រោយមកព្រះនាងម៉ារីទៅជាម្តាយរបស់ព្រះជា ម្ចាស់ពិតមែន។

ហេតុនេះហើយ សូមបងប្អូនទុកអត្ថបទទី២របស់សន្តយ៉ាកុបនៅក្នុងដួងចិត្តរបស់យើង "**អ្នកឯង មានជំនឿ រីឯខ្ញុំខ្ញុំប្រព្រឹត្តអំពើល្អ សូមបង្ហាញជំនឿរបស់អ្នកដែលគ្មានប្រព្រឹត្តអំពើល្អឱ្យខ្ញុំមើលមក នោះខ្ញុំនឹងបង្ហាញឱ្យអ្នកឃើញជំនឿរបស់ខ្ញុំដោយអំពើល្អដែលខ្ញុំបានប្រព្រឹត្ត**"។ ជំនឿរបស់យើង ណែនាំឱ្យមានផ្លែ ជំនឿរបស់យើងត្រូវការមានផ្លែ ផ្លែដែលឆ្ងាញ់បំផុត ដែលផ្អែមបំផុត គឺសេចក្តី ស្រឡាញ់។ ប្រសិនបើ ជំនឿរបស់យើងឥតមានផ្លែសោះ មានតែការអធិដ្ឋាន មានតែការទូលអង្វរ ព្រះជាម្ចាស់លើកលែងទោសឱ្យយើង ហើយទុកចោលបងប្អូនដែលកំពុងជិតដាច់ដង្ហើម ជំនឿ របស់យើងជាជំនឿបីដូចជាជំនឿសាបសូន្យ។ សន្ត វ៉ាំងសង់ឌឺប៉ូល ជាសន្តដែលបានខិតខំបង្ហាញ ធម៌មេត្តាករុណាអស់មួយជីវិតរបស់គាត់ នៅពេលមានស្ត្រីម្នាក់មកសួរគាត់ថា "**លោកឪពុកខ្ញុំ កំពុងអធិដ្ឋាននៅក្បែរព្រះកាយព្រះគ្រីស្ត និងប្រសិនបើមានអ្នកសុំទានមករំខានខ្ញុំដើម្បីសុំឱ្យខ្ញុំទៅ ជួយគាត់ តើឱ្យខ្ញុំត្រូវធ្វើអ្វី? ឱ្យខ្ញុំបន្តអធិដ្ឋាន ឬឱ្យខ្ញុំទៅជួយគាត់**"។ លោកឪពុកគាត់បានឆ្លើយថា "**ដូចគ្នា នៅពេលយើងអង្គុយអធិដ្ឋានក្បែរព្រះយេស៊ូ និងនៅពេលយើងកំពុងជួយបងប្អូនដែលមាន ទុក្ខលំបាក យើងជួបជាមួយព្រះយេស៊ូដូចគ្នា**" ដោយសារនេះជាផ្លែនៃជំនឿរបស់យើង គឺសេចក្តី ស្រឡាញ់។

ដូច្នេះ បងប្អូនជាទីស្រឡាញ់ឱ្យយើងយល់ថាពិតមែន ព្រះជាម្ចាស់បានណែនាំឱ្យយើងរស់នៅក្នុងសេចក្ដីសង្ឃឹម ព្រះជាម្ចាស់បានប្រទានជំនឿឱ្យយើងដើម្បីមានកម្លាំងទៅមុខ។ ជំនឿរបស់យើងត្រូវការចែករំលែកនៅក្នុងផ្លែដ៏ពិសេសគឺចិត្តមេត្តាករុណា ចិត្តអាណិតអាសូរយ៉ាងជាក់ស្ដែង។ ខ្ញុំបានឃើញវីដេអូរបស់ប្អូនៗ មានច្រើនបានរើសវីដេអូបង្ហាញអំពីការចែករំលែកដល់ចាស់ជរាដល់កូនក្មេង ដល់អ្នកជំងឺ ដល់អ្នកសុំទានតាមផ្លូវ។ ជាស្នាដៃរបស់យើងនៅក្នុងជំនឿរបស់យើងមានខ្លះទៀតបង្ហាញនៅពេលគេអធិដ្ឋាន នៅពេលគេរៀបចំព្រះវិហារ នេះជាជីវិតរបស់យើងជាគ្រីស្ដបរិស័ទ។ ទាំងការអធិដ្ឋាន ទាំងការបម្រើនៅក្នុងជំនឿ ដើម្បីបង្ហាញផ្លែដែលយើងបានទទួល។ ហេតុនេះហើយ ខ្ញុំសូមអញ្ជើញព្រះសហគមន៍នីមួយៗ ឱ្យបន្តផ្លូវដែលយើងបានចាប់ផ្ដើមនៅក្នុងសន្និបាតនេះ។ មានព្រះសហគមន៍ខ្លះ មិនបានជួបជុំគ្នាជាមួយយុវជនពីយូរខែមកហើយ ដូច្នេះក្នុងសន្និបាតនេះយើងបានឃើញព្រះសហគមន៍ធំក្ដី តូចក្ដី បានយកចិត្តទុកដាក់។ យើងបានឃើញយុវជនពោរពេញដោយថាមពល ពោរពេញដោយកម្លាំងកាយកម្លាំងចិត្តលុះត្រាតែយើងថែរក្សាយកចិត្តទុកដាក់លើពួកគាត់។ ដូច្នេះ ខ្ញុំសូមអញ្ជើញព្រះសហគមន៍នីមួយៗតាមរយៈលោកឪពុក តាមរយៈបងប្រុសបងស្រីបន្តយកចិត្តទុកដាក់លើផ្លូវដែលយើងបានចាប់ផ្ដើមថ្ងៃនេះ។

ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដោយសារខ្ញុំឃើញជំងឺកូវីដ-១៩បានណែនាំឱ្យយើងភ័យខ្លាចមែនទែន កូវីដ-១៩បានណែនាំឱ្យបងប្អូនជាច្រើនបាត់បង់ជីវិត បាត់បង់មុខរបរ បាត់បង់ការងារ...។ ប៉ុន្តែ កូវីដ-១៩បានណែនាំឱ្យយើងប្រហែលជិតស្និទ្ធជាមុន ជិតស្និទ្ធនៅក្នុងរបៀបថ្មី យើងបានឃើញថ្ងៃនេះយ៉ាងជាក់ស្ដែង ទំនាក់ទំនងដែលយើងធ្លាប់បង្កើតពីមុន នៅក្នុងរបៀបពេលហ្នឹងណែនាំឱ្យទំនាក់ទំនងរបស់យើងដូចជារីកចម្រើនថែមទៀត បានទៅមុខថែមទៀត។ យើងធ្លាប់និយាយថា ការសួរសុខទុក្ខគ្នាសំខាន់ណាស់ ប៉ុន្តែនៅក្នុងទំនាក់ទំនងពីចម្ងាយ (Online) តាមរបៀបដែលយើងបានជួបជុំគ្នានៅកន្លែងនីមួយៗ យើងបានសួរសុខទុក្ខគ្នាទៅវិញទៅមក។ ជាក់ស្ដែងនៅក្នុងទំនាក់ទំនងផ្ទាល់តាមកន្លែងនីមួយៗ និងរួមគ្នាតាមរយៈជួបគ្នាពីចម្ងាយ យើងបានសួរសុខទុក្ខគ្នាទៅវិញទៅមក ដូច្នេះឱ្យយើងពោរពេញដោយមោទនភាព។ ខ្ញុំសង្ឃឹមថា នៅតាមកន្លែងនីមួយៗ នៅតាមព្រះសហគមន៍នីមួយៗ នៅតាមមណ្ឌលសកម្មភាពនីមួយៗ នៅក្នុងជីវិតរបស់យើងម្នាក់ៗ ឱ្យយើងពោរពេញដោយសេចក្ដីក្លាហាន ឱ្យយើងពោរពេញដោយកម្លាំង។

បងប្អូនជាទីស្រឡាញ់ យើងអាចធ្វើបាននៅក្នុងព្រះអំណោយទានរបស់ព្រះជាម្ចាស់ ដូចព្រះយេស៊ូមានព្រះបន្ទូលដល់ស្ត្រីសាម៉ារី "**ប្រសិនបើស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ នាងនឹងពោរពេញដោយសេចក្តីសុខនិងសុភមង្គល**"។ ខ្ញុំជឿថា យើងមានសំណាងណាស់ដោយសារយើងបានស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ខ្លះៗហើយ។ យើងមិនទាន់ស្គាល់ពេញលក្ខណៈ យើងស្គាល់ខ្លះៗណែនាំឱ្យយើងអាចទៅមុខតទៅទៀត ណែនាំឱ្យយើងធ្វើអ្វីៗទាំងអស់បាន។ ជាមួយទំនុកតម្កើងដែលយើងបានស្ដាប់នៅថ្ងៃនេះ យើងអាចទុកសម្រាប់ជីវិតរបស់យើង "**ខ្ញុំស្រឡាញ់ព្រះម្ចាស់ ត្បិតទ្រង់ព្រះសន្តាប់ខ្ញុំ ខ្ញុំលែងសោកទួញយំ ទទួលសុំទូលអង្វរ**"។ ពិតមែនខ្ញុំស្រឡាញ់ព្រះជាម្ចាស់ ព្រះជាម្ចាស់ទ្រង់ស្ដាប់ខ្ញុំ នៅពេលខ្ញុំយំ នៅពេលខ្ញុំអស់សង្ឃឹម ក៏ព្រះអង្គទទួលដែរ។

សូមព្រះអង្គប្រទានព្រះពរដល់ព្រះសហគមន៍របស់យើង ដល់យុវជនយុវនារីទាំងអស់ ដើម្បីឱ្យយើងរួមគ្នាយើងបន្តធ្វើដំណើរ នៅក្នុងសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ផ្ទាល់។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

(73) 12-09-2021 ធម្មទេសនារបស់លោកអភិបាល អូលីវីយេ ក្នុងអភិបូជាបិទសន្និបាតយុវជនកាតូលិកភូមិភាគភ្នំពេញ២០២១ - YouTube